# របៀបដាក់ពាក្យជ្រើសរើសវិទ្យាល័យ




1. ចូលប្រើប្រាស់ប្រព័ន្ធ ParentVue តាមរយៈគេហទំព័រ lbschools.net ឬបើកក្នុងអាប់កម្មវិធី ParentVue
2. ចុចលើឈ្មោះសិស្សដែលរៀន ថ្នាក់ទី 8
3. ចុចលើ រូប ជម្រើសវិទ្យាល័យ
4. ចុចលើពាក្យ មាតាបិតាសិស្សថ្នាក់ទី8 - ហើយចុចបើក/Open **បែបបទពាក្យសុំជ្រើសរើសវិទ្យាល័យ (SOC Application)**
5. **ជំហ៊ាន ទី1-3៖** សូមអានអំពីរាល់ជំហ៊ាននីមួយៗឱ្យបានល្អិតល្អន់។ សូមចុចលើពាក្យ ‹‹បន្ទាប់/Next›› នៅផ្នែកខាងក្រោម នៃទំព័រនីមួយៗ
6. **ជំហ៊ាន ទី4៖** សូមទទួលស្គាល់គោលការណ៍ច្បាប់នានារបស់មន្ទីរអប់រំ៖ សូមចុចលើប្រអប់សំណួរនីមួយៗ។ អ្នកមិនអាចបំពេញ ការដាក់ពាក្យទៅមុខទៀតបានទេ លុះត្រាតែអ្នកទទួលស្គាល់គោលការណ៍របស់មន្ទីរអប់រំទាំងនេះជាមុនសិន។ ហើយបន្ទាប់មក ចុចលើពាក្យ ‹‹បន្ទាប់/Next››។
7. **ជំហ៊ានទី5៖ សាលាក្នុងតំបន់រស់នៅ៖** សូមជ្រើសរើសកម្មវិធីសិក្សាជំនាញអាជីព (pathway) នៅវិទ្យាល័យក្នុងតំបន់រស់នៅ ហើយចុចលើពាក្យ ‹‹បន្ទាប់/Next›› *<u>ចំណាំ៖</u> បន្ទាប់មកទៀត លោកអ្នកអាចដូរលំដាប់លេខរៀងវិទ្យាល័យដែលអ្នកជ្រើសរើសបាន ប៉ុន្តែអ្នកមិនអាចដកជម្រើសវិទ្យាល័យដែលស្ថិតក្នុងតំបន់រស់នៅរបស់អ្នក ចេញបានឡើយ។* (ប្រសិនបើអ្នកមិនរស់នៅក្នុងតំបន់ព្រំដែនកំណត់របស់មន្ទីរអប់រំ LBUSD ទេនោះ គឺលោកអ្នកនឹងមិនឃើញ ផ្ទាំងអេក្រង់នេះ បង្ហាញចេញមកទេ)។
8. **ជំហ៊ានទី6៖ ការជ្រើសរើសវិទ្យាល័យ៖** អ្នកនឹងមើលឃើញកម្មវិធីសិក្សាទាំងអស់ដែលមានបង្ហាត់នៅតាមវិទ្យាល័យ ដែលសិស្សថ្នាក់ទី8 របស់អ្នកមានលក្ខខណ្ឌអាចចូលរៀនបាន។ អ្នកអាចជ្រើសរើសកម្មវិធីសិក្សាជំនាញអាជីព បានរហូតដល់ 3មុខ។
9. **ជំហ៊ានទី7៖ បញ្ជាក់ និង រៀបជម្រើសសាលាតាមលំដាប់លេខរៀងដែលខ្លួនចង់បាន៖** សូមប្រាកដ ត្រូវរៀបជម្រើសសាលារបស់អ្នកតាមលំដាប់លេខរៀងដែលខ្លួនចង់បាន។ លេខរៀង ទី1 គឺជាជម្រើសដែលពេញចិត្តបំផុត រីឯលេខរៀង ទី4 គឺជាជម្រើសដែលចូលចិត្តចុងក្រោយបង្អស់។ ដើម្បីដូររលំដាប់លេខរៀង សូមចុចលើលេខរៀងនោះ ហើយជ្រើសរើស លេខរៀងថ្មីមួយវិញ។
10. **ជំហ៊ានទី8៖ បញ្ជាក់ផ្ទៀងផ្ទាត់ជម្រើសសាលា៖** សូមត្រួតពិនិត្យពាក្យស្នើសុំរបស់អ្នកឡើងវិញ។ ប្រសិនបើមានការកែប្រែចាំបាច់ត្រូវធ្វើ សូមចុចលើពាក្យ ‹‹ទំព័រមុន/Previous›› ដើម្បីត្រឡប់ថយទៅទំព័រក្រោយវិញ។ សូមបញ្ចូលឈ្មោះរបស់អ្នក ឱ្យដូចគ្នាបេះបិតទៅនឹងអ្វីដែលវាបង្ហាញដូច្នោះដែរ ដើម្បីបញ្ជាក់ពីការជម្រើសសាលារបស់អ្នក។ សូមចុចលើ ពាក្យ ‹‹Yes/No›› ហើយរើសយកពាក្យ «Yes» ដើម្បីបញ្ជាក់ពីជម្រើសសាលារបស់អ្នកជាចុងក្រោយ ទុកជាការស្រេច។  ហើយបន្ទាប់មក សូមចុចលើពាក្យ ‹‹បន្ទាប់/Next››។
11. **ជំហ៊ានទី8៖** បញ្ចប់ការដាក់ពាក្យ។ (អ្នកអាចមើលឃើញ រូបអបអរលោតភ្លឺផ្អេក) សូមចុចលើ ប៊ូតុងនោះ ដើម្បីព្រីនឯកសារដាក់ពាក្យជ្រើសរើសសាលារបស់អ្នក ជាទម្រង់ ភីឌីអែហ្វ/pdf។

ដើម្បីធ្វើការកែប្រែ៖ (ត្រូវតែបំពេញឱ្យបានចប់សព្វគ្រប់ នៅត្រឹមម៉ោង 4:00ល្ងាច នៅថ្ងៃទី12 ខែធ្នូ ឆ្នាំ2025)

- សូមចូលមើលជំហ៊ានទី8។ សូមចុចលើ ពាក្យ ‹‹Yes/No›› ហើយរើសយកពាក្យ ‹‹ទេ/No›› វិញ
- សូមវាយបញ្ចូលឈ្មោះរបស់អ្នក ជាថ្មីឡើងវិញ
- សូមចុចត្រឡប់ថយក្រោយ គ្រប់ទំព័រទាំងអស់របស់បែបបទដាក់ពាក្យសុំនោះ ដើម្បីធ្វើការកែប្រែបើចាំបាច់ផ្សេងៗ។
- សូមចូលមើលជំហ៊ានទី8។ ត្រួតពិនិត្យឡើងវិញ អំពីការជ្រើសរើសថ្មីរបស់អ្នក
- សូមវាយបញ្ចូលឈ្មោះរបស់អ្នក ជាថ្មីឡើងវិញ ដើម្បីបញ្ជាក់អំពីជម្រើសសាលារបស់អ្នក
- សូមចុចលើ ពាក្យ ‹‹Yes/No›› ហើយរើសយក «Yes»  ដើម្បីបញ្ជាក់ពីជម្រើសសាលារបស់អ្នកជាចុងក្រោយ ទុកជាការស្រេច។ រួចចុចលើពាក្យ ‹‹បន្ទាប់/Next›› ហើយ គឺចប់ ជាស្ថាពរ។

**ទូរសព្ទជំនួយផ្នែក ជម្រើសវិទ្យាល័យ (562) 997-8306 — HSMSChoicehelp@lbschools.net**